ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ២០០៧ អពដ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មីនា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង
## អំពីកម្រិតការប្រាក់ទីផ្សារសម្រាប់ប្រាក់រៀល ខ្ចីឆ្នាំ២០១៤

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១៨ នៃច្បាប់ស្តីពីសារពើពន្ធ ផ្នែកទី២.៥ និងផ្នែកទី៥.៩ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញលេខ១០៥៩ ប្រក.សហវ.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ និងយោងតាមសេចក្តីណែនាំអំពីការកំណត់ចំណាយការប្រាក់របស់សហគ្រាសលេខ១៥១ អពដ.ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារបានកំណត់អត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់រៀល ខ្ចីឆ្នាំ២០១៤ ចំនួន **១៣.៥២%** ក្នុងមួយឆ្នាំ។ ដោយធនាគារពាណិជ្ជធំៗក្នុងស្រុកភាគច្រើនមិនមានសេវាផ្តល់កម្ចីជាប្រាក់រៀល អត្រាការប្រាក់នេះត្រូវបានគណនាពីមធ្យមភាគនៃអត្រាការប្រាក់ឱ្យខ្ចីជាប្រាក់រៀល របស់ធនាគារពាណិជ្ជធំៗក្នុងស្រុកចំនួន ៤(បួន)។

អាស្រ័យហេតុនេះគ្រប់អង្គភាពពន្ធដារ និងគ្រប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ចំពោះលទ្ធផលសារពើពន្ធសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៤ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋាន ពន្ធដារ

គង់ វិបុល

**ចម្លងជូន:**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពពន្ធដារ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh